# ការសម្ភាសន៍របស់លោកតា សុម តោ

កៈ អ្នកសម្ភាសន៍គេមាន រត្ន ពិសី ខៈ អ្នកដែរគេត្រូវសម្ភាសន៍មាន សុម តោ

<u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់លោកតា សុម តោ</u>

ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់លោកតា សុម តោហើយគាត់មានការឆ្លងកាត់នៅពីរសង្គ្រាមគឺសង្គ្រាមលន់នល់និងសង្គ្រាមប្រល័យពូជសាសន៍ប៉ុលពតហើយគាត់បានឆ្លងកាត់ដោយការលំបាកហើយគាត់មានការទទួលខុសត្រូវប្រពន្ធកូនហើយគាត់បានធ្វើការដោយប្រើកម្លាំងកាយខ្លួនឯងដោយពិតៗហើយបានតស៊ូនៅឧបសគ្គជាច្រើននៅក្នុងជីវិតរបស់គាត់ហើយគាត់ជាអ្នកបានឆ្លងកាត់នៅបញ្ហាទាំងឡាយរបស់គាត់ហើយគាត់ជាសាក្សីមួយតែបានជួបនៅបញ្ហាអស់ទាំងនេះ។ហើយគាត់ជាមនុស្សម្នាក់ស្លូត ហើយសុភាពគ្មានការទះទែញជាមួយអ្នកណាទេនៅក្នុងភូមិនិងនៅក្នុងកន្លែងការងារ។ធ្វើឡើងនៅភូមិខ្ពប ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល កណ្ដាល ធ្វើឡើងនៅថ្ងៃទី ១៦ ខែ ០៦ ឆ្នាំ ២០១៨។

កៈ ជាដំបូងខ្ញុំសូមជំរាប់សួរខ្ញុំបាទមានឈ្មោះថា រត្ន ពិសី បានសូមអនុញ្ញាតលោកតាធ្វើការសម្ភាសន៍ជីវប្រវត្តិរបស់លោកតាហើយខ្ញុំធ្វើឡើងដោយសាកលវិទ្យាល័យមួយដែរមានឈ្មោះថាសាកលវិទ្យាល័យ BYU ហើយដើម្បីថែរក្សាជីវប្រវត្តិរបស់កុងហើយនិងដើម្បីថែរក្សាជីវប្រវត្តិរបស់ជីដូនជីតារបស់កុងអញ្ជឹងណាស់កុងដើម្បីទុកឲ្យកូនចៅជំនាន់ក្រោយរបស់កុងគាត់បានស្ដាប់ហើយបានដឹងថាកុងមានការលំបាកហើយនិងបានជួបនៅឧបសគ្គជាច្រើននៅក្នុងជីវិតរបស់កុងអញ្ជឹងណាស់កុង។

ខៈ បាទ! ដូចខ្ញុំប្រាប់អញ្ជឹងមានការលំបាកណាស់ចៅ។

កៈ បាទ! ហើយអញ្ជឹងដើម្បីទុកឲ្យគាត់បានស្ដាប់អញ្ជឹងណាស់ថាអ្នកជំនាន់មុនមានការលំបាកអ្វីខ្លះអញ្ជឹងណាស់កុង។

ខៈ បាទ! ត្រឹមត្រូវហើយ។

កៈ បាទ! ហើយអញ្ចឹងក្មួយធ្វើឡើងនៅថ្ងៃទី ១៦ ខែ ០៦ ឆ្នាំ ២០១៨ ។ហើយអញ្ចឹងណាស់កុងហើយអញ្ចឹងអត់ទោសកុងមានឈ្មោះអីដែរកុង?

ខៈ ខ្ញុំមានឈ្មោះថា សុម តោ ។

កៈ បាទ!ហើយអញ្ចឹងមានឈ្មោះថា សុម តោ ។

ខៈ បាទ!

កៈ ហើយអញ្ចឹងកុងមានឈ្មោះឡូយណាស់កុង។

ខៈ បាទ!

កៈ ហើយអញ្ចឹងកុងមានឈ្មោះហៅក្រៅទេកុង?

ខៈ អត់មានទេមានតែមួយនឹងណា។

កៈ បាទ! ហើយអញ្ចឹងកុងអត់មានទេមានឈ្មោះតែមួយទេកុង?

ខៈ បាទ!

កៈ បាទ!ហើយអញ្ចឹងសព្វថ្ងៃនិងកុងមានប្រជន្មប៉ុន្មានហើយកុង?

ខៈ ខ្ញុំមានអាយុ៨០ឆ្នាំហើយឆ្នាំថ្មីនិងណា។

កៈ បាទ! ហើយអញ្ចឹងកុងសព្វថ្ងៃនិងកុងមានប្រជន្ម៨០ឆ្នាំហើយបើគិតពីឆ្នាំថ្មីកុង។

ខៈ បាទ!

កៈ ហើយអញ្ចឹងខ្ញុំឃើញកុងនៅសង្ហាកុង?

ខៈ បាទ! ហើយខ្ញុំរាល់ថ្ងៃនិងត្រូវភ្នែកឈឺ។

កៈ បាទ!កុងឈឺភ្នែកកុង។

ខៈ បាទ!

កៈ ហើយអញ្ចឹងកុងមានចាំថ្ងៃខែឆ្នាំកំណើតរបស់កុងទេកុង?

ខៈ បាទ!ខ្ញុំកើតនៅឆ្នាំ ថោះ ។

កៈ បាទ!

ខ៖ ហើយខ្ញុំកើតនៅឆ្នាំ ១៩៣៨។

ក៖ បាទ! ហើយអញ្ចឹងកុងកើតនៅឆ្នាំ
១៩៣៨ណាកុងណោះហើយអញ្ចឹងបើឆ្នាំខ្មែរយើងនិងឆ្នាំថោះ។

ខ៖ បាទ! បើឆ្នាំខ្មែរយើងនិងឆ្នាំ ថោះ។

ក៖ បាទ! ហើយអញ្ចឹងកុងមានចាំទីកន្លែងកំណើតរបស់កុងទេកុង?

ខ៖ បាទ! ខ្ញុំចាំតើ។ហើយខ្ញុំពីដើមមកនិងខ្ញុំកើតនៅខេត្តកំពង់ឆ្នាំងទេ។

ក៖ បាទ! ហើយអញ្ចឹងកុងអ្នកនៅខេត្តកំពង់ឆ្នាំងទេណោះកុង?

ខ៖
អត់ទេនៅស្រុកនិងកាលពីដើមនិងឪពុកម្ដាយខ្ញុំនិងគាត់ក្រីក្រហើយគាត់ទៅចាប់ដីហើយ
កាប់ដីរានព្រៃហើយគាត់យកទៅដាំពោតក្រហមនិងណា។

ក៖ បាទ!

ខ៖ ហើយគាត់រានព្រៃនិងដាំពោតទៅណានៅខេត្តកំពង់ឆ្នាំងនិងទៅ។

ក៖ បាទ! ហើយអញ្ចឹងគាត់នៅខេត្តកំពង់ឆ្នាំងនិងទៅកុង។

ខ៖ បាទ!ហើយខ្ញុំពេលនិងនៅខេត្តកំពង់ឆ្នាំង ឃុំ ព្រៃគ្រប់និង។

ក៖ បាទ!

ខ៖ ហើយនៅស្រុក ស្ទឹងត្រង់ហើយនិងគាត់នៅដាំពោតក្រហមនៅនិងទៅណាស់។

ក៖ បាទ! ហើយអញ្ចឹងកុងបានកើតនៅខេត្ត
កំពង់ឆ្នាំងហើយអញ្ចឹងកុងបាននៅនិងដែរណាកុងណោះ។

ខ៖ បាទ!
ហើយខ្ញុំកើតនៅនិងហើយពេលនិងពេលដល់ខែទឹកឡើងទៅហើយវាលិចអស់និងទៅហើ
យបានសម្រេចចិត្តមកនៅនិងវិញមកទៅណាស់។
ក៖ បាទ! ហើយអញ្ចឹងកុងអ្នកនៅកំពង់ឆ្នាំងទេ។

ខ៖ ខ្ញុំនិងកើតនៅនឹងមែនណាស់ហើយគ្រាន់តែម៉ាកើតទេណា។

ក៖ បាទ!

ខ៖ ហើយពេលដល់ទឹកវាលិចហើយគាត់បានមកនៅនិងវិញមកណាស់។

ក៖ បាទ! ហើយអញ្ចឹងបានមកនៅនិងវិញមកណាកុង។

ខ៖ បាទ!
ហើយគាត់មានស្រុកកំណើតគាត់នៅនិងហើយគាត់បានមកនៅស្រុកកំណើតគាត់វិញមកណា។

ក៖ បាទ!

ខ៖ បាទ!
ហើយគាត់មកនៅកោះឧកញ៉ាតីនិងវិញមកណាហើយកាលនិងគាត់ដាំពោតបន្លែបង្កាហើយកាលនិងស្រុកសុទ្ធតែព្រៃហើយគាត់បានរានព្រៃដាំពោតក្រហមនិងណាស់ហើយគាត់រកនៅនឹងអត់បានហើយគាត់បានត្រលប់មកវិញមកណាស់។

ក៖ បាទ! និយាយចឹងបងប្អូនបង្កើតរបស់កុងនឹងមានប៉ុន្មាននាក់ដែលកុង?

ខ៖
បងប្អូនខ្ញុំមាន៦នាក់ទាំងអស់៧ហើយបានស្លាប់១នឹងស្រីតែរាល់ថ្ងៃនឹងខ្ញុំនឹងបានស្លាប់១ចឹងទៅនៅសល់តែ៦នាក់នឹងទេរាល់ថ្ងៃនឹងហើយចឹងកាលនឹងខ្ញុំនៅសល់នឹង៦នាក់ដល់ចឹងទៅខ្ញុំនឹងបានស្លាប់១ទៀតចឹងខ្ញុំនៅសល់តែ៥នាក់ទេរាល់ថ្ងៃនឹងខ្ញុំនឹង។

ក៖ អូចឹងបងប្អូនរបស់កុងនឹងបាននៅសល់តែ៥នាក់ទេ?

ខ៖ អូនឹងហើយបងប្អូនខ្ញុំនឹងបានសល់តែ៥នាក់នឹងទេ។

ក៖ ចុះកុងនឹងជាកូនទីប៉ុន្មានហើយកុង?

ខ៖ ខ្ញុំនឹងមើលកូនខ្ញុំនឹងជាកូនទី២ទី៣អូខ្ញុំនឹងជាកូនទី៤។

ក៖ ចុះកូនដែលបានចាំឈ្មោះបងប្អូនកុងទេ?

ខ៖ ថ្វីមិនចាំ។

ក៖ បាទចឹងបងកយងទី១នឹងមានឈ្មោះអីដែលកុង?

ខ៖
បងខ្ញុំបង្អូសស្រីដែលគាត់នឹងបានស្លាប់បាត់ហើយកាលនឹងខ្ញុំនឹងមិនបានកើតទាន់ទេកាលនឹងហើយក្រោយមកនឹងបងខ្ញុំនឹងគាត់មានឈ្មោះថាបង

សិយរាល់ថ្ងៃនឹងគាត់បានរស់នៅកំពុងចាមបងខ្ញុំនឹងក៏គាត់ស្រីដែលតែគាត់បានស្លាប់បាន ២ឆ្នាំហើយរាល់ថ្ងៃនឹងខ្ញុំនឹងនៅមានបងស្រីខ្ញុំដែលគាត់នឹងបាននៅកោះនឹងក៏គាត់នឹងរៀង ចាស់ហើយរាល់ថ្ងៃនឹងគាត់នឹងបានដើររៀងកោងដែលហើយគាត់នឹងបានទៅវត្តនឹងរាល់ ថ្ងៃនឹងហើយនឹងដែលជាបងខ្ញុំដែលគាត់នឹងបាននៅរស់រាល់ថ្ងៃនឹងបងខ្ញុំនឹងគាត់មានអាយុ នឹង៨០ជាងហើយនឹងរាំថ្ងៃនឹងខ្ញុំនឹងបានទៅលេងគាត់ដែលនឹងហើយខ្ញុំនឹងបានរាល់ថ្ងៃនឹង ខ្ញុំនៅមានបងខ្ញុំហើយនឹងខ្ញុំរាល់ថ្ងៃនឹងបានខ្ញុំនឹងទៅមើលគាត់នឹងហើយខ្ញុំនឹងក៏ចាស់ដែល ចឹងកាលណាខ្ញុំនឹងបានទៅកុំអោយខ្ញុំនឹងបានឈឺចឹងកាលនឹងបាទ។

ក៖ បាទចឹងកាលនឹងប្អូនកុងនឹងគាត់មានឈ្មោះអីដែលកុង?

ខ៖ ប្អូនខ្ញុំនឹងមានឈ្មោះថាហៀង។

ក៖ ចុះពៅគេកុងគាត់មានឈ្មោះអីដែលកុង?

ខ៖ ពៅគេនឹងគាត់មានឈ្មោះ សំមួន។

ក៖ តែកុងនឹងមានឈ្មោះថាតោ?

ខ៖ បាទខ្ញុំនឹងមានឈ្មោះថាតោ។

ក៖
កុងនិយាយពីចាស់រឿងដែលថាកុងកាលនឹងដែលកុងជាមួយនឹងបងប្អូនកុងកាលនឹងធ្លាប់ ពិបាកនឹងជាមួយនឹងគ្នាកាលនឹងដែលមានទេកុងកាលនឹង?

ខ៖
ពីដើមខ្ញុំនឹងមិនមានកាងារអីធ្វើនឹងគេទេកាលនឹងហើយខ្ញុំនឹងបានធ្វើតែកម្មកចិនកាលនឹង លើហើយនឹងរ៉ែងចឹងទេកាលនឹងដល់ក្រោយមកខ្ញុំមកខ្ញុំនឹងមិនបានធ្វើអីទេកាលនឹងដល់ កាលនឹងគេនឹងបានមានសង្គ្រាមជាមួយនឹងជប៉ុនហើយនឹងបារាំងចឹងទៅកាលនឹងកាលនឹ ងខ្ញុំនឹងបាននៅតូចៗនឹងហើយខ្ញុំនឹងបានរស់នៅក្នុងវត្តទេកាលនឹង។

ក៖ ហេតុអីកាលនឹងកយងបានទៅរស់នៅក្នុងវត្តកាលនឹងកុង?

ខ៖ កាលនឹងខ្ញុំនឹងបានទៅរស់នៅក្នុងវត្តនឹងខ្ញុំនឹងបានរៀនភាសាបារាំងកាលនឹងជំនាន់ អឺ អុយ
កាចឹងកាលនឹងជំនាន់ដើមនឹងកាលនឹងយើងនឹងបានរស់នៅជាមួយនឹងបារាំងកាលនឹង។

ក៖ បាទ!

ខ៖
កាលនឹងយើងនឹងបានរស់នៅជាមួយនឹងបាននឹងហើយកាលនឹងខ្ញុំនឹងបានរស់នៅក្នុងវត្តនឹងកាលនឹងដល់លោកឆាន់កាលនឹងយើងនឹងបានក្រោនកន្ទេនឹងអោយលោកកាលនឹងបានឆាន់ហើយកាលនឹងខ្ញុំនឹងបានចាប់ចាបកាលនឹងយកមកដុយកាលនឹងអោយបានទៅជាខ្លោតចឹងទៅយកមកជូតក្តាគលកាលនឹងហើយជំនាន់នឹងខ្ញុំនឹងបានយកដីឥដ្ឋយកទៅធ្វើដីសរហើយកាលនឹងខ្ញុំនឹងបានរៀននៅក្នុងវត្តចឹងទៅកាលនឹងហើយខ្ញុំនឹងបានរៀនតែមួយៗទេកាលនឹងហើយយលងនឹងបានរៀនកាលនឹងយើងរៀនបានក្រោលរៀនទៅកាលនឹងខ្ញុំដល់រួចចឹងទៅឪពុកមាខ្ញុំកាលនឹងគាត់បានបួត។

ក៖ អូរកាលនឹងកយងមានឪពុកមានឹងបានបួសទៀតកាលនឹងកុង?

ខ៖
នឹងហើយកាលនឹងលោកបួតនៅក្នុងវត្តនឹងកាលនឹងហាយលោកបានហៅខ្ញុំអោយបានមករៀននឹងកាលនឹងទៅរៀនជាមួយនឹងលោកវិញកាលនឹងកាលនឹងលោកបានហៅខ្ញុំនឹងអោយទៅនៅវត្តកាលនឹងដែលបាននៅខេត្តកំពុងចាមកាលនឹងវត្តកោះសូទ្រិនកោះពែងនឹងកាលនឹង។

ក៖
អូកុងកាលនឹងតើកុងនឹងបងប្អូនកុងកាលនឹងដែលបានចូលចិត្តធល្វកាងារអីជាមួយនឹងគ្នាទេកាលនឹង?

ខ៖
មិនបានធល្វអីទេកាលពីដើមកាលនឹងកាលនឹងខ្ញុំនឹងបានដើររកត្រីហើយនឹងបាធ្វើតែចំការនឹងទិចទួចកាលនឹងមិនបានធ្វើអីទេកាលនឹងខ្ញុំនឹងហើយកាលនឹងខ្ញុំនឹងមិនបានធ្វើពោងចក្រកាលនឹងហើយខ្ញុំនឹងមិនបានធ្វើអីទេកាលនឹងខ្ញុំនឹងបានតែលើដីហើយនឹងបានធ្វើអីតិចតួចនិងហើយកាលនិងមានអីធ្វើកាលនិងនោះ។

ក៖ បាទ!

ខ៖ ហើយអ្នកណាគេមានកម្លាំងគេធ្វើឈើទៅណាស់។

ក៖ បាទ!

ខ៖ បាទ!
ហើយដើរកាប់ឈើនៅតាមព្រៃភ្នំទៅណាហើយដល់ពេលធំឡើងអញ្ចឹងណាស់។ហើយខ្ញុំបានត្រលប់មកវិញអញ្ចឹងណាស់។

កៈ បាទ!

ខៈ បាទ! ហើយកាលនិងនៅឆ្នាំ
១៩៨៤ទៅ៨៥និងណាស់ហើយជប៉ុនវាចូលទៅក្នុងភ្នំពេញនឹងណាស់ហើយ។

កៈ បាទ!

ខៈ ហើយកាលនិងជប៉ុនចូលមកចាប់បារាំងនិងណាស់។

កៈ បាទ!

ខៈ ហើយជប៉ុនមកចាប់បារាំងនិងហើយបារាំងរត់មកនៅលើកោះនិងណាស់។

កៈ បាទ! ហើយអញ្ចឹងបារាំងរត់ទៅវិញ។

ខៈ បាទ!
បារាំងនិងកាលនិងវាទូលស្រូវរត់មកលើកោះនិងពួនគមន៍ព្រៃនិងហើយកាលនិងខ្ញុំនៅវត្ត
នៅឡើយទេ។

កៈ បាទ! ហើយអញ្ចឹងកុងនៅវត្តទេ។

ខៈ បាទ! អត់ទាន់ទៅកំពង់ចាមទេ។

កៈ បាទ!

ខៈ បាទ!
ហើយកាលនិងបារាំងនៅពួនក្នុងព្រៃនិងហើយកាលពីដើមព្រៃវាទូលខ្ពស់ៗកាលនិងពីដើម
និងអីមានផ្ទះទេណាស់មានអ្នកណាគេឃើញសុទ្ធតែព្រៃនិងណាស់។

កៈ បាទ! កុង។

ខៈ
គ្មានអ្នកណាគេរកឃើញទៅហើយខ្ញុំដើរទៅឃើញវាហើយវាថាកូរហើយខ្ញុំអត់ចេះបារាំងនិ
ងអត់ដឹងថាវាត្រូវការអីអញ្ចឹងណាស់អត់ដឹងសោះនិងបានអត់ដឹងវាថាមិចអញ្ចឹងណាស់។

កៈ បាទ!

ខៈ ហើយវាថាកូរៗនិងណាស់វាស្រែកទឹក។

កៈ បាទ! ហើយកាលនិងអត់ដឹងថាវាធ្វើអីអញ្ចឹងណាស់។

ខ៖ បាទ! វាស្រែកទឹកព្រោះអីវានៅក្នុងព្រៃនិងណាស់។

ក៖ បាទ!

ខ៖ ហើយកាលណាកូនហើយណាប្ដីប្រពន្ធនៅរងារនិងណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយស្រែកឲ្យជួយអញ្ចឹងណាស់។

ក៖ បាទ!

ខ៖ ព្រោះអីវាខ្លាចរថគ្រោះ។

ក៖ បាទ! កាលនិងវាខ្លាចរថគ្រោះកុង។

ខ៖ បាទ! កាលនិងវាខ្លាចរថគ្រោះនិងព្រោះអីជប៉ុនចូលដល់ភ្នំពេញហើយនិង។

ក៖ បាទ!

ខ៖ ហើយរួចទៅពេលនិងដល់ឆ្នាំ១៩៤៥
និងណាស់ហើយខ្ញុំរុះផ្ទះនៅខាងលិចនិងណាស់។

ក៖ បាទ!

ខ៖ បាទ!
ហើយរុះពីភូមិខាងលិចនិងណាស់ព្រោះអីឪពុកពីដើមគាត់ទៅរស់នៅជាមួយគ្នាអញ្ចឹងណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយខ្ញុំបានមកដល់ភូមិខាងនេះវិញម្ដាយមីងគាត់ឲ្យមកនៅនិងណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយគាត់បានមកវិញទៅណាស់។

ក៖ បាទ!

ខ៖ ហើយគាត់ថាឲ្យកូនអញមកនៅនិងអញមានកូនប្រុសតែមួយផងនិង។

កៈ បាទ!

ខៈ បាទ! ហើយក៏នៅនិងទៅណាស់។

កៈ បាទ!

ខៈ ហើយក៏នៅទៅសាកូនសាត្រាវនិងហើយពេលនិងជប៉ុនទម្លាក់គ្រាប់បែកទៅណាស់។

កៈ បាទ!

ខៈ បាទ! កាលនិងណាស់។

កៈ បាទ!

ខៈ ហើយកាលនិងនៅឆ្នាំសង្គ្រាមលោកទី២និងជំនាន់អេវ្លែនិងណាស់។

កៈ បាទ!

ខៈ ហើយមកហោះតាមនិងដូចយន្តហោះមករាល់ថ្ងៃនិងណាស់។

កៈ បាទ!

ខៈ ហើយពីដើមយន្តហោះមានលឿនដូចអញ្ចឹងណា។

កៈ បាទ!

ខៈ លឺសម្លេងវ៉េវហើយចាស់ៗពីដើមមានទៅស្គាល់អីទេ។

កៈ បាទ!

ខៈ ហើយចាស់ៗបានជីកត្រេងសេនិងជិតផ្ទះគាត់និងណាស់។

កៈ បាទ!

ខៈ ហើយឲ្យតែឃើញយន្តហោះអង្គុយមើលនិង។

កៈ បាទ! ហើយអញ្ចឹងគាត់អត់ដឹងថាយន្តហោះកំពុងទម្លាក់គ្រាប់បែកនិងកុង។

ខៈ បាទ! ពីដើមមានណាអត់ដឹងផងនិង។

កៈ បាទ!

ខ៖ ហើយមានអ្នកគិតថាមានការទម្លាក់គ្រាប់បែកនិងណាស់។

ក៖ បាទ!

ខ៖ ហើយអត់មានការស្គាល់ផងនិង។

ក៖ បាទ! ហើយអញ្ជឹងគាត់នៅអង្គុយមើលថាដូចកង់ហើរនិងកុង។

ខ៖ បាទ! ហើយបានលឺគេទម្លាក់គ្លឹងៗ។

ក៖ បាទ!

ខ៖ ហើយកាលនិងដឹងថាគេទម្លាក់គ្រាប់បែកនិងហើយ។

ក៖ បាទ!

ខ៖ ហើយគេថាទម្លាក់គ្រាប់បែកអញ្ជឹងតា។

ក៖ បាទ!

ខ៖
ហើយពីជំនាន់អេឡូនិងយើងមានចេះដឹងថាអីនិងណាស់គ្រាន់តែមានកាំភ្លើងនិងអត់ដឹងថាបាញ់មិចផងនិង។

ក៖ បាទ!

ខ៖ ហើយកាលនិងបារាំងវារត់ទៅក្នុងព្រៃអត់ហើយនិង។

ក៖ បាទ! ហើយគេរត់បាត់ទៅក្នុងព្រៃនិងហើយយើងមានដឹងអី។

ខ៖ បាទ!
ហើយកាលនិងបានជប៉ុននៅផ្សារនិងណាស់ហើយគេហៅបងប្រុសខ្ញុំនិងហើយនិងឪពុកខ្ញុំនិងណាស់។

ក៖ បាទ!

ខ៖ ហើយលឺគ្រាប់លឺអីនិងហើយនៅសល់ម៉ាស៊ីនគិនពោតនិងរាល់ថ្ងៃនិងណាស់។

ក៖ បាទ!

ខ៖ បាទ!
ហើយជប៉ុនវាទម្លាក់ម៉ាស៊ីនកាណូតវានិងលឺខ្ទុលនិងដល់សព្វថ្ងៃនិងហើយវាទម្លាក់ឯងចោលទៅណាស់។

ក៖ បាទ!

ខ៖ ហើយវាទៅស្រុកវាវិញទៅណាស់។

ក៖ បាទ!

ខ៖ ហើយពេលជប៉ុន
មកនិងហើយអាបារាំងនិងវារត់ទៅនៅក្នុងព្រៃនិងហើយវារួចខ្លួនវាទៅណាស់។

ក៖ បាទ! ហើយពួកគាត់បានរួចខ្លួនមួយពេលទៅ។

ខ៖ បាទ !រួចខ្លួនមួយពេលទៅណាស់។

ក៖ បាទ!

ខ៖ ហើយកាលនិងជប៉ុនវាចាញ់សង្គ្រាមនិង។

ក៖ បាទ! កាលនិងវាចាញ់សង្គ្រាមហើយនិងកុង។

ខ៖ បាទ! កាលនិងវាចាញ់សង្គ្រាមហើយនិងណាស់ហើយវាយកពីនិងទៅទាំងអស់និង។

ក៖ បាទ!

ខ៖ អរដល់អញ្ចឹងបារាំងចូលស្រុកហើយខ្ញុំនិងបានទៅនៅវត្តកោះប៉ែន។

ក៖ បាទ! វត្តនៅកោះប៉ែនវត្តនៅកំពងចាម?

ខ៖ វត្តកំពងចាមនឹងក្រោចវត្តដីដោះនឹង។

ក៖ បាទ!ក្រោយវត្តដីដោះ?

ខ៖ ក្រោយដល់ទឹកឡើងខ្ញុំអីសអុញៗជាប់ក្នុងវត្តនឹង។

ក៖ បាទ!

ខ៖ ម៉ាលខ្ញុំនឹងហើយលោកធ្វើចំការហួសព្រែកជីកហាន់ថ្នាំអោយលោកនៅព្រែកនឹង។

កៈ បាទ!

ខៈ ទៅភ្នំនៅវត្តនឹងនៅនឹង។

កៈ បាទ!នៅនឹង?

ខៈ
នៅនឹងជាមួយលោកហើយថ្នាំម៉ាកអីនៅគាត់នៅនឹងដល់ហើយដើរមកវិញចាស់ៗគេថាអោយមកវត្តវិញហើយជំនាន់នឹងយាយនៅកោះគាត់និយាយថាឯងម៉ងទៅស្រុកហើយឪឯងឡើកស្រាក់ឪឯងប្រយ័ត្នបើពីដើមវាពិបាកដើរកាព៉ារដឹកអួសមានតាមួយមិនស្រួលដូចឥឡូវនឹងណា។

កៈ បាទ!

ខៈ
មកស្រុកគាត់ថាអេឯងមកធ្វើអីឪយាយគាត់ថាធ្វើស្រាក់អីណាមកស្រុកវិញវានៅវត្តក្បាលកោះដល់មកឪពុកខ្ញុំគាត់នៅនឹងនៅនឹងទៅនៅរៀននៅវត្តនឹងទៅរៀន ក ខ ជាមួយលោកនៅនឹងទៅ។

កៈ បាទ!រៀន ក ខ ជាមួយលោក?

ខៈ បាទ!មានវត្តក្បាលកោះនឹងមានវត្តអីច្រើនមកពីណារៀននៅនឹងទៅក ខ ស្រែកពេញទំហឹងទៅពីដើមដល់ពេលរួតទៅគេបង្កើតសាលាវត្តស្បៅមុនដំបូងឈ្មោះ គង់គាត់ជាអ្នកបង្រៀនា
ិចឹងទៅលោកនៅស្រុកនឹងគាត់ជាអ្នកបង្រៀននៅសាលាទៅខ្ញុំរៀនតាមគុតរៀននៅសាលាមូលហើយដល់ពេលនិងសាលានិងហើយនិងរៀនដល់លោកគ្រូវ៉ាត់ទៀតណាស់។

កៈ បាទ! ហើយកាលនិងកុងរៀនជាមួយលោកៗទៅកុង។

ខៈ បាទ!
ខ្ញុំកាលនិងខ្ញុំរៀនជាមួយលោកនិងណាស់ដល់ស្រុកកាលនឹងវានឹងរៀងស្ងត់កាលនឹងព្រោមលោកវ៉ាតៅកាលនឹងគាត់បាននៅមុនវត្តភ្នំកាលនឹងជំនាន់នឹងបារាំងនឹងបានអុកលុកជំនាន់នឹងហើយកាលនឹងឪពុកខ្ញុំកាលនឹងគាត់បានធ្វើគាត់បានធ្វើពូជៅកាលនឹងហើយកាលនឹងឪពុកខ្ញុំគាត់បានទៅ២ហើយនឹង៣នាក់កាលនឹងទៅយកកាំភ្លឹកាលនឹងដែលជប៉ុនកាលនឹងវានឹងបានដាក់ចោលកាលនឹងហើយទៅនឹងយកអត់បានទេកាលនឹងហើយកាលនឹងវាស្និតតេបានបត់ចៃនកាលនឹង។

កៈ អូចឹងកាលនឹងគេនឹងបានបត់ចឹងកាលនឹងកុង?

ខ៖ កាលនឹងគេនឹងបានទុកបានបត់ចឹងកាលនឹង។

ក៖ បាទចឹងកាលនឹងយកមកប្រើនឹងមិនបានទេកុង?

ខ៖ ប្រើមិចបានកាលនឹងព្រោះអីអត់ចេះផងនិងមានអីកាលមានក៏អត់ប្រយោជន៍ទេ។

ក៖ បាទ! អត់ប្រយោជន៍កុងណោះកុង។

ខ៖ បាទ!
ហើយកាលនិងយកតែកាំបិតអាសារិះកាលនិងហើយកាលនិងគេហៅថាកាំបិតសារិះនិង
កាលនិងហើយមានប្រវែងណែកាលនិង។

ក៖ បាទ!

ខ៖
ហើយខ្ញុំយកមកហើយកាលនិងមានអីណាយកកាំបិតសៀតនិងចង្កឹះនិងជាមួយកាំបិតសា
រិះនិង។

ក៖ បាទ!

ខ៖ ហើយកាលនិងយកមកចែកគ្នាអញ្ជឹងណាស់។

ក៖ បាទ! កាលនិងយកមកចែកគ្នាណាកុង។

ខ៖ បាទ!
ហើយចាស់អាណាគេយកគ្រាប់បែកៗនិងមានបានប្រយោជន៍អីកាលនិងហើយគេលូញដី
ឥដ្ឋនិងហើយលាបពណ៌ខ្មៅៗ។

ក៖ បាទ! លាបពណ៌ខ្មៅនិងកុង។

ខ៖ បាទ! ហើយកាលនិងមានថ្នាំណាលាបមានតែរបស់បារាំងនិងណាស់។

ក៖ បាទ!

ខ៖ ហើយយកទៅលាបទៅ។

ក៖ បាទ!

ខ៖ ហើយកាំភ្លើងនិងមានអីអត់ប្រយោជន៍និងណាស់។

ក៖ បាទ!

ខ៖ ហើយយកទៅបោះចោលនៅកន្លែងណាទេមានតែប៉ុណ្ណឹងណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយកាលពាក់ខ្សែកាថាលោកប្រសិទ្ធនិងណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយកាលនិងសរសេរខ្សែកាថានិងដាក់សុទ្ធតែរូបព្រះនិងណា។

ក៖ បាទ!

ខ៖ បាទ!កាលនិងបារាំងបានមកសុំនិងណាស់។

ក៖ បាទ!

ខ៖
ហើយកាលនិងលោកវ៉ាតែតនិងលោកមករង់វេងនិងណាស់ហើយលោកបានឆ្លងតាមទូកដរនិងហើយលោកមកនិងណាស់ហើយខ្ញុំកាលនិងបានជួបគាត់និងខ្ញុំសួរគាត់ចុះឡើងហើយគាត់ចង្អុលទៅភ្នំពេញនិង។

ក៖ បាទ!

ខ៖
ហើយខ្ញុំកាលនិងខ្ញុំអត់ចេះបារាំងផងនិងហើយគាត់អត់ចេះខ្មែរដែរនិងសួរចុះឡើងគាត់ចង្អុលទៅភ្នំពេញនិងណាស់។

ក៖ បាទ !

ខ៖ ហើយខ្ញុំថាលោកមិនទៅភ្នំពេញទៅ។

ក៖ បាទ!

ខ៖ ហើយថ្ងៃក្រោយនិងបារាំងជឿលោកវ៉ាតែលនិងគាត់ជឿរនិងណាស់។

ក៖ បាទ!

ខ៖ ហើយកាលនិងគាត់ហែរទណ្ឌិនមករាល់ឆ្នាំណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយរួចហើយលោកនិមន្តលោកទៅលេងនៅក្បាលម៉ាស៊ីន។

ក៖ បាទ!

ខ៖ បាទ! ហើយគាត់ដំហែលទណ្ឌិនមករាល់ឆ្នាំហើយដំហែលនិងអត់មានភ្លើងនិងហើយយកម៉ាស៊ីនមកដាក់ឲ្យទៀត។

ក៖ បាទ!ហើយអញ្ចឹងគាត់ដាក់ភ្លើងឲ្យទៀតកុង។

ខ៖ បាទ! គាត់ដាក់ភ្លើងឲ្យទៀតណា។

ក៖ បាទ!

ខ៖ ហើយគាត់យកសុទ្ធក្បាលដែកនិងបានមកផ្សារជាបង្គល់ភ្លើងឲ្យទៀត។

ក៖ បាទ! ហើយអញ្ចឹងកុងមានចាំឈ្មោះឪពុកម្ដាយរបស់កុងទេកុង?

ខ៖ ខ្ញុំចាំតើ។

ក៖ បាទ! ហើយអញ្ចឹងគាត់មានឈ្មោះអីដែរកុង?

ខ៖ គាត់មានឈ្មោះថា អ៊ែម សុម ។

ក៖ បាទ! ហើយអញ្ចឹង អ៊ែម សុម និងលោកឪពុកមែនកុង?

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងអ្នកម្ដាយមានឈ្មោះអីដែរកុង?

ខ៖ ហើយបើអ្នកម្ដាយគាត់មានឈ្មោះថា សឿន ខុត ។

ក៖ បាទ! គាត់មានឈ្មោះថា សឿន ខុត កុង។

ខ៖ បាទ!

ក៖ បាទ! គាត់មានឈ្មោះដូចបារាំង។

ខ៖ បាទ! គាត់មានឈ្មោះដូចបារាំង។

ក៖ បាទ! ហើយគាត់កើតនៅជំនាន់បារាំងហើយមានឈ្មោះដូចបារាំងទៀត។

ខ៖ បាទ!

ក៖ បាទ!
ហើយអញ្ចឹងកុងមានចាំថាគាត់មានអាយុប៉ុន្មានទេពេលគាត់បានចែកឋានទៅអញ្ចឹងណាស់?

ខ៖
បាទ!ពេលនិងគាត់មានអាយុប៉ុន្មានទេហើយអញ្ចឹងបានរាល់ថ្ងៃនិងខ្ញុំចេះតែគិតថាកាលពីជំនាន់អាពតហើយដល់ចប់ជំនាន់អាពតហើយនិងអត់ដឹងថាគាត់មានអាយុប៉ុន្មានអញ្ចឹងណាស់។ហើយកាលនិងខ្ញុំត្រូវគេជំលៀសចេញអស់ហើយតើហើយខ្ញុំពេលនៅសង្គ្រាមលន់នល់និងខ្ញុំគេជំលៀសចេញហើយដែរនិង។

ក៖ បាទ!

ខ៖ បាទ! ហើយខ្ញុំបានមកនៅឡើងផ្ទះ ថៅកែខ្ញុំគេឲ្យខ្ញុំនិងទៅនៅផ្ទះជិតព្រំដែនថៃទេ។

ក៖ បាទ!

ខ៖ ហើយគាត់ថាឯងទៅនៅថៃទៅហើយយើងមានកូនបីបួននៅនិងហើយណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយយើងទៅខ្លួនទទេមិចបានទៅចោលប្រពន្ធកូនរត់ទៅនៅម្នាក់ឯងមិចបាន។

ក៖ បាទ! ហើយឲ្យយើងរត់ទៅម្នាក់ឯងមិចកើតមានកូនហើយមានប្រពន្ធនៅនិងនោះ។

ខ៖ ហើយយើងមានប្រពន្ធនៅនិងអញ្ចឹងណាស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំទៅដេកនៅអូរជ្រៅនិងហើយខ្ញុំដឹកឈើពីស្វាយស៊ីសាផុននិងណាស់។

ក៖ បាទ!

ខ៖ ហើយគេថាទៅនៅហើយទៅដល់ហើយទៅដេកនៅនឹងណាស់។

ក៖ បាទ!

ខ៖ ហើយកាលនិងដេកហើយគេអត់ឲ្យចេញ។

ក៖ បាទ!

ខ៖ ហើយមុខដំបូងគេឲ្យទៅហើយគេអត់ឲ្យចេញវិញ។

ក៖ បាទ! ហើយអញ្ជឹងគេអត់ឲ្យចេញវិញកុង។

ខ៖ បាទ! គេអត់ឲ្យចេញវិញនិងណាស់។

ក៖ បាទ!

ខ៖ ហើយដេកចាំនៅក្បែរនិងគោលស្ពាននៅក្បាលដើមនិង។

ក៖ បាទ!

ខ៖ បាទ!ហើយវាអត់ហើយអត់ឲ្យទៅហើយដេកស្ដាប់វ៉ាយូ(វិទ្យុ)និងហើយកាលនិងមានអីណាមានតែវ៉ាយូ(វិទ្យុ) និងហើយណាស់ហើយកាលនិងមានអីមានតែវ៉ាយូ(វិទ្យុ)ហើយស្ដាប់ទៅណាស់។

ក៖ បាទ!

ខ៖ បាទ! ហើយគេនិយាយថាវាយដល់ព្រៃលួងហើយ។

ក៖ បាទ!

ខ៖ ហើយគេថាព្រៃលួង ស្រុកព្រៃអំពិលហើយខ្ញុំថាវីដល់ស្រុកអញហើយតើហើយមិនទន្ទឹមគ្នាហើយខ្ញុំថាហើយប្រពន្ធខ្ញុំមិចហើយទេ។

ក៖ បាទ!

ខ៖ ហើយខ្ញុំគិតហើយប្រពន្ធអញទៅជាយ៉ាងណាទេហើយខ្ញុំគិតពីនិងទៅណាស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំគិតពីនិងហើយខ្ញុំមកផ្ទះហើយ។

ក៖ បាទ!

ខ៖ ហើយអញ្ជឹងបានមកប្រាប់ថៅកែនៅនិងហើយខ្ញុំថាខ្ញុំមកផ្ទះហើយ។ហើយខ្ញុំថាវាយដល់ព្រៃលួងព្រៃហោហើយប្រពន្ធខ្ញុំអត់ដឹងថាមិចទេហើយខ្ញុំមកហើយខ្ញុំប្រាប់ហើយ។ហើយគា

ត់ថាខ្ញុំធ្វើមិចហើយខ្ញុំថាប្រាប់អង្គហ្វៃនិងមកយកក្បាលរថភ្លើងនិងមកវិញមកហើយឈើអត់ទាន់ធ្លាក់ពីការុងណា។

ក៖ បាទ!

ខ៖ ហើយនៅជិតនៅគោលស្ពាននិងទៅណាស់។

ក៖ បាទ!

ខ៖
ហើយយើងមានស្ពានជិះហើយមានម្ខាងរទេះភ្លើង(រថភ្លើង)ហើយម្ខាងផ្លូវឡានអញ្ចឹងណាស់។

ក៖ បាទ! ហើយមានម្ខាងផ្លូវរថភ្លើងហើយនិងម្ខាងទៀតផ្លូវឡាន។

ខ៖ បាទ!
កាលនិងគេដាក់ប្រាស(រនាង)ហើយគេដាក់ពាកកណ្តាលអញ្ចេកហើយម្ខាងខ្មែរម្ខាងថៃអញ្ចឹងណាស់។

ក៖ បាទ!

ខ៖ ហើយខ្ញុំនៅខាងខ្មែរនិង។

ក៖ បាទ! ហើយបើយើងឆ្លងពីស្ពានរថភ្លើងនិងហើយដល់ថៃ។

ខ៖ បាទ! នឹងហើយឆ្លងនិងទៅដល់ថៃហើយនិង។

ក៖ បាទ! ហើយអញ្ចឹងកុងអត់ទៅនឹកប្រពន្ធពេក?

ខ៖ បាទ! ហើយគេអត់ឲ្យចេញឈើនិង។

ក៖ បាទ! គេអត់ឲ្យចេញឈើនិងកុង។

ខ៖ បាទ! គេអត់ឲ្យចេញឈើនិងណាស់។

ក៖ បាទ!

ខ៖
ហើយដូចថាគេអ្នកទិញឈើអញ្ចឹងណាស់ហើយយើងនិងជាអ្នកដឹងឈើទៅណាស់ហើយពេលយើងបានទៅយើងទៅធ្វើការនៅរោងចក្រទេទៅណាស់។

កៈ បាទ! គេមានរោងចក្រឲ្យយើងធ្វើការដែរកុង។

ខៈ បាទ! គេឲ្យធ្វើងារតើហើយតែខ្ញុំគិតដល់ប្រពន្ធចង់ប្រកាចយុលហើយនិងមានពេលណាធ្វើការហើយបើខ្ញុំធ្វើការហើយពេលលឺថាគេវាយហើយធ្វើការមិចកើតនៅគិតដល់កូនចៅនិងណាស់។

កៈ បាទ!

ខៈ ហើយគេថាធ្លាក់នៅស្វាយស៊ីសាផុនហើយគេថាចាំជិះយន្តហោះនៅព្រលានយន្តហោះបាត់ដំបងនិងណាស់ហើយគេឲ្យខ្ញុំនិងជិះទៅ។

កៈ បាទ!

ខៈ បាទ! ហើយគេហៅអីទេកាត្រីជីកនិងណាអីមិចទេកាលនិងនោះ។

កៈ បាទ!

ខៈ ហើយដូចគេហៅស្អីគេនិងអាកាប៉ាលហោះ(យន្តហោះ)អីគេនិងណាស់គេហៅអេប៊ូតា៥២ គេមិចគេនិងណាស់ហើយជិះ។

កៈ បាទ!

ខៈ ហើយខ្ញុំជិះប៉ុណ្ណឹងពីភ្នំពេញនិងណាស់ហើយជិះរត់ប្រុចនិងហើយគ្រាន់តែខ្ញុំប្រាប់គេថាខ្ញុំទៅផ្ទះហើយ។

កៈ បាទ!

ខៈ ហើយពេលបានមកដល់ផ្ទះហើយបានមកដល់សព្វថ្ងៃនិងណាស់ធ្លាប់ឆ្លងកាត់អស់ហើយសង្គ្រាមនោះ។

កៈ បាទ!

ខៈ បាទ! ហើយកាលនិងមិនស្រួលណាគ្រាប់ផ្លោមចុះឡើងមិនស្រួលទេណាស់។

កៈ បាទ!

ខៈ ហើយកាលនិងសង្គ្រាមបារាំងនិងជប៉ុននិងណាស់។

កៈ បាទ! ហើយអញ្ចឹងកុងមានចាំឆ្នាំខ្មែររបស់គាត់អត់កុង។

ខៈ បាទ!

កៈ ឆ្នាំខ្មែររបស់គាត់កុងមានចាំអត់កុង?ដូចជាឪពុកម្ដាយរបស់កុងណាស់ដូចជា ជូត ឆ្លូវ ខោល ថោះអញ្ចឹងណាស់កុងមានចាំទេ?

ខៈ បាទ! អត់ចាំទេ។

កៈ បាទ! ហើយអញ្ចឹងអត់ចាំទេកុង។

ខៈ បាទ!

កៈ បាទ! ហើយអញ្ចឹងទីកន្លែងកំណើតគាត់កុងមានចាំអត់កុង?

ខៈ បាទ! គាត់នៅកើតនិងណាស់។

កៈ បាទ! ហើយអញ្ចឹងគាត់ជាអ្នកនៅកោះឧកញ៉ាតីនៅនិងម៉ងកុង?

ខៈ បាទ! គាត់ជាអ្នកកោះនិងម៉ងនឹងណា។

កៈ បាទ!
ហើយអញ្ចឹងកុងមានចាំថាគាត់ប្រកបមុខរបស់អីដើម្បីចិញ្ចឹមកុងអញ្ចឹងណាស់កុង?

ខៈ បាទ!

កៈ បាទ!ហើយអញ្ចឹងគាត់ប្រកបមុខរបរអីដើម្បីចិញ្ចឹមកុងអញ្ចឹងណាស់កុង?

ខៈ អូរ! គាត់មានធ្វើអីក្រៅពីរកត្រី។

កៈ បាទ! គាត់រកត្រី។

ខៈ បាទ! ហើយគាត់មានអីធ្វើទេ។

កៈ បាទ! ដូចជាគាត់ធ្វើស្រែចំការអញ្ចឹងកុង។

ខៈ បាទ! គាត់ធ្វើចំការនិងធ្វើស្រែនិងមានធ្វើអីទេ។

កៈ បាទ! ហើយអញ្ជឹងគាត់ជាមនុស្សបែបណាដែរកុងហើយឬគាត់ជាអ្នកកាចឬក៏គាត់អ្នកស្លូតដែរកុង។

ខៈ បាទ! គាត់ជាមនុស្សធម្មតាទេគាត់នឹងបានស្លូតគាត់នឹងមិនបានកាចទេគាត់នឹង។

កៈ គាត់ដែលបានវ៉ៃកុងទេកាលនឹង?

ខៈ អត់ទេ។

កៈ ចឹងកាលនឹងកុងដែកបានខូចអោយគាត់នឹងបានវ៉ៃទេកាលនឹង?

ខៈ ហើយកាលនិងលោកឪពុកខ្ញុំគាត់នេះដែរព្រោះគាត់និងស្លូតដែរទេហើយគ្រាន់តែគាត់កូនប្រុសតែមួយទេ។

កៈ បាទ!ហើយអញ្ជឹងគាត់ជាកូនប្រុសមួយនៅក្នុងគ្រួសារកុង។

ខៈ បាទ! ហើយប៉ាខ្ញុំនិងគាត់មានកូនស្រីពីរ។

កៈ បាទ! គាត់មានកូនស្រីពីរ។

ខៈ បាទ! ហើយឪពុកខ្ញុំនិងគាត់ស្រឡាញ់ចៅរបស់គាត់ណាស់។

កៈ បាទ!

ខៈ ហើយដឹងតាមគេនិយាយប្រាប់ខ្ញុំទេណាស់។

កៈ បាទ!

ខៈ បាទ! ហើយគាត់ថាឪពុកឯងណាតាឯងគាត់ថ្នមតាំងពីតូចមកហើយគាត់ដើរទៅណាតិចកូនសុទ្ធតែវ៉ៃរែក។

កៈ បាទ! ពេលគាត់ទៅណាសុទ្ធតែរែក។

ខៈ គាតស្រឡាញ់កូនគាត់ណាស់។

កៈ បាទ! ហើយអញ្ជឹងគាត់ស្រឡាញ់កូនគាត់ពេកកុងណោះ។

ខៈ បាទ! គាត់ស្រឡាញ់ណាស់។

កៈ បាទ! ហើយអញ្ចឹងអ្នកម្ដាយវិញកុងគាត់កាចអត់កុង?

ខៈ ហើយម្ដាយខ្ញុំអត់ទេគាត់កាន់ខាងសិល្បៈដែរនិង។

កៈ បាទ! ហើយអញ្ចឹងអ្នកម្ដាយរបស់កុងជាអ្នកសិល្បៈកុង។

ខៈ បាទ!គាត់ខាងសិល្បៈ ។

កៈ បាទ! ហើយអញ្ចឹងគាត់ចេះរាំរបាបានច្រើនកុងណោះ។

ខៈ បាទ! គាត់របាព្រះរាជទ្រព្យ។

កៈ បាទ! គាត់ចេះរាំរបាព្រះរាជទ្រព្យកុង។

ខៈ បាទ! ហើយកាលនិងតាំងពីសម្ដាចតាហើយនិងជំនាន់ល
ន់នល់និងហើយនិងជំនាន់បារាំងនិងគេហៅគាត់ទៅរាំអញ្ចឹងណាស់។

កៈ បាទ! ហើយអញ្ចឹងម្ដាយរបស់គាត់ស្អាត់ដែរកុងហើយអ្នករាំមួយៗមិនធម្មតាទេកុង?

ខៈ បាទ! ហើយខ្ញុំពីដើមតាមគាត់និងដែរនិង។

កៈ បាទ!ហើយអញ្ចឹងកុងទៅតាមគាត់ដែរកុង។

ខៈ បាទ! ហើយខ្ញុំទៅតាមគាត់ដែរនិង។

កៈ បាទ! ហើយអញ្ចឹងកុងមាននៅចាំសាច់រឿងកុងជាមួយឪពុកម្ដាយទេកុង?

ខៈ បាទ!ហើយខ្ញុំនៅចាំតើ។

កៈ បាទ!
ហើយអញ្ចឹងមានបានទៅណាខ្លះទេកុងហើយដូចបានទៅដើរលេងជាមួយគាត់អញ្ចឹងណាស់មានចាំទេកុង?

ខៈ
អត់មានទៅណាទេខ្ញុំនៅជាប់ជាមួយគាត់និងរហូតនិងម៉ងនិងណាហើយតាំងពីជំនាន់អាពតនិងមកហើយកាលនិងនោះ។

កៈ បាទ!

ខៈ បាទ! ហើយខ្ញុំចេញទៅទៀតគាត់នៅនឹងណាស់។

កៈ បាទ!

ខៈ ហើយខ្ញុំបានមកពីនិងវិញហើយខ្ញុំនៅនិងទាល់តែចប់។

កៈ បាទ!

ខៈ ខ្ញុំធ្វើការជាមួយក្បួនមហាសាគរនេះហើយគាត់មានបងប្អូនខាងខ្សែលន់នល់។

កៈ បាទ!

ខៈ បាទ! ហើយពីដើមគេហៅខ្ញុំហើយពីដើមក្រោយផ្ទះនិងទន្លេ។

កៈ បាទ! ក្រោយផ្ទះកុងនិងទន្លេកុង។

ខៈ បាទ! នៅឆ្នាំ១៩៧០កាប៉ាលគេដាក់ឈើហុបនិងយកចេញទៅក្រៅទៅណាស់។

កៈ បាទ!

ខៈ ហើយគេយកទៅលក់នៅហុងកុង សាំងកំព្បូរ ម៉ាឡេស៊ី
និងហើយកាលជប៉ុនចូលទៅខ្ញុំធ្វើឈើនៅនិងគ្មានអ្នកណាចូលទេ។

កៈ បាទ! ហើយអញ្ចឹងកុងធ្វើឈើនៅនិងកុង។

ខៈ បាទ!
ខ្ញុំធ្វើឈើហុបនៅនិងវាស់ឈើនិងហើយដាក់ចូលក្នុងកាប៉ាល់អីទៅហើយដល់កំពង់សោម
អីទេហើយចេះក្រែងទៅណាស់។

កៈ បាទ! ហើយអញ្ចឹងកុងមានចាំឈ្មោះជីដូនជីតាខាងឪពុកខាងម្ដាយទេកុង?

ខៈ ឪពុកខ្ញុំនឹង។

កៈ បាទ!

ខៈ ឈ្មោះឪពុកគាត់មានឈ្មោះថា តា អ៊ែម យាយ នួន។

កៈ បាទ! ហើយអញ្ចឹងខាងអ្នកម្ដាយវិញកុងមានចាំទេ?

ខៈ ហើយខាងម្ដាយឈ្មោះតា បាវាំង ។

កៈ បាទ! ឈ្មោះតា បាវាំង។ហើយអញ្ចឹងឈ្មោះលោកយាយមានឈ្មោះអីដែរកុង?

ខ៖ ហើយបើយាយខ្ញុំអត់ដឹងព្រោះអីជំនាន់យាយខ្ញុំនិងខ្ញុំអត់កើតទាន់ទេ។

ក៖ បាទ!

ខ៖ ហើយខ្ញុំដឹងតាមគេមកឈ្មោះយាយ ញ៉ឹក ។

ក៖ បាទ! មានឈ្មោះយាយញ៉ឹក ។

ខ៖ បាទ! នឹងខ្ញុំគ្រាន់បានដឹងពីមីងខ្ញុំដែរនិង។

ក៖ បាទ! ហើយអញ្ចឹងកុងជាអ្នកខេត្តកណ្ដាលនៅនិងម៉ង។

ខ៖ បាទ! ខ្ញុំនៅនឹងម៉ងណា។

ក៖ បាទ!
ហើយអញ្ចឹងកុងមានបងប្អូនជីដូនមួយហើយនិងជីទួតមួយដែរមានទៅស្រុកឆ្ងាយទេ?ហើយដូចជានៅអាមេរិច កាណាដា អូស្ត្រាលី កូរ៉េអីនឹងកុងមានទេ?

ខ៖ អត់មានទេ។

ក៖ បាទ! ហើយអញ្ចឹងកុងអត់មានទេ?

ខ៖ បាទ!

ក៖ បាទ!ហើយអញ្ចឹងបច្ចុប្បន្ននិងអត់មានទេដែរគាត់ទៅបម្រើការងារនៅប្រទេសថៃហើយនិងកូរ៉េមានទេ?

ខ៖ អត់មានទេរាល់ថ្ងៃនិងណាស់អត់មានទេកូននៅក្នុងស្រុកទាំងអស់និងណាស់។

ក៖ បាទ! ហើយអញ្ចឹងកុងបើនិយាយពីភរិយារបស់កុងវិញគាត់មានឈ្មោះអីដែរកុង?
ខ៖ បាទ! អត់ដែរ។

ក៖ បាទ! ភរិយារបស់កុងមានឈ្មោះអីដែរកុង?

ខ៖ អត់មានធ្វើអីដែរនិង។

ក៖ បាទ! ដូចអញ្ចេកកុងភរិយារបស់កុងមានឈ្មោះអីដែរកុង?

ខ៖ ភរិយារបស់ខ្ញុំមានឈ្មោះ ពៅ។

ក៖ បាទ! គាត់មានឈ្មោះ ពៅ។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងទាំងត្រកូលគាត់មានឈ្មោះអ្វីដែរកុង?

ខ៖ អរគាត់មានឈ្មោះថា ថៃម ពៅ។

ក៖ បាទ! ថៃម ពៅ។

ខ៖ គាត់និងទើបតែស្លាប់តែនិង។

ក៖ បាទ! ហើយអញ្ចឹងគាត់ទើបតែស្លាប់និងកុង។ហើយគាត់ស្លាប់បានប៉ុន្មានឆ្នាំដែរ?

ខ៖ គាត់ស្លាប់នៅឆ្នាំ ១៩៩២និង។

ក៖ បាទ! ហើយអញ្ចឹងគាត់ស្លាប់១៩៩២កុង។

ខ៖ បាទ! គាត់ស្លាប់ដោយសារគាត់ឈឺធ្មេញហើយហើមរីក។

ក៖ បាទ! ហើយអញ្ចឹងគាត់កើតមហារីកធ្មេញកុង?

ខ៖ បាទ!នឹងហើយ។

ក៖ បាទ!

ខ៖ បាទ! ហើយគាត់ធ្លាយអាថ្កាលនិងញុំាបាយអត់កើតនិង។

ក៖ បាទ!

ខ៖ ហើយគាត់ស្លាប់ទៅណាស់។

ក៖ បាទ! ហើយអញ្ចឹងកុងរៀបការនៅនឹងម៉ងកុង។

ខ៖ បាទ! ខ្ញុំការនៅនឹងម៉ង។

ក៖ បាទ!
ហើយអញ្ចឹងកុងការបានប៉ុន្មានឆ្នាំដែរកុង?ហើយអញ្ចឹងកុងការតាំងពីជំនាន់លន់នល់។

ខ៖ អត់ទេខ្ញុំការមុនជំនាន់លន់នល់ទៀត។

ក៖ បាទ!ហើយអញ្ចឹងកុងការពីជំនាន់សម្តាចតា។

ខ៖ បាទ! វាក្បែរៗនិងណាស់។

ក៖ បាទ! ក្បែរៗនិង។

ខ៖ បាទ! កាលនិងខ្ញុំនៅក្មេងៗដែរណាស់។

ក៖ បាទ! ហើយអញ្ចឹងកុងមានកូនប៉ុន្មាននាក់ដែរកុង?

ខ៖ ចង់និយាយថាសព្វថ្ងៃនិង។

ក៖ បាទ!

ខ៖ កូនទាំងអស់គឺ ប្រាំបីនាក់។ហើយស្លាប់អត់មួយនៅសល់ប្រាំពីរ។

ក៖ បាទ! ហើយអញ្ចឹងស្លាប់អស់មួយនៅសល់ប្រាំពីរ។

ខ៖ បាទ! ហើយសព្វថ្ងៃនេះនៅប្រាំមួយប្រាំពីរនាក់ដែរ។

ក៖ បាទ!
ហើយអញ្ចឹងកុងមានចាំឈ្មោះពួកគាត់ទេថាកូនបងគេបង្អស់មានឈ្មោះអីគេដែរកុង?

ខ៖ ហើយអាបងនៅក្បាលភូមិនិងមានឈ្មោះ វារី។

ក៖ បាទ! មានឈ្មោះថា វារី។ហើយអញ្ចឹងកូនទីពីរកុងមានឈ្មោះអ្វីដែរកុង?

ខ៖ មានឈ្មោះអាធីវាមកមិញនឹង?

ក៖ បាទ! គាត់មានឈ្មោះធីហើយអញ្ចឹងបងស្រីប្រពន្ធគាត់បង?

ខ៖ បាទ! អត់ទេអាមិញនិង។

ក៖ បាទ! ហើយអញ្ចឹងបងមិញនិងកុង។

ខ៖ បាទ! ហើយមិញដើរនិងឈ្មោះអាធី។

ក៖ បាទ! ហើយអញ្ចឹងកូនទីបីមានឈ្មោះអីដែរកុង?

ខ៖ ហើយអាទីបីវានៅមុខនាក។

ក៖ បាទ! គាត់នៅមុខផ្ទះកុងនឹងកុងហើយអញ្ចឹងគាត់មានឈ្មោះអ្វីដែរកុង?

ខ៖ វានិងមានឈ្មោះថាអាចិន្តា។

ក៖ បាទ! មានឈ្មោះចិន្តា។ហើយអញ្ចឹងកូនទីបួនមានឈ្មោះអ្វីដែរកុង?

ខ៖ ហើយទីបួននៅឯកើត។

ក៖ បាទ! គាត់នៅកើតកុងហើយអញ្ជឹងគាត់មានឈ្មោះអ្វីដែរកុង?

ខ៖ វានិងមានឈ្មោះថាអាឌី។

ក៖ បាទ! កូនទីបួនមានឈ្មោះឌី។ហើយអញ្ជឹងកូនទីប្រាំមានឈ្មោះអ្វីដែរកុង?

ខ៖ ហើយពល់ថ្ងៃមានឈ្មោះអីទៀតមានឈ្មោះអីទេអរមានឈ្មោះ លាង និង ធារី។

ក៖ បាទ! មានឈ្មោះថា លាង និង ធារី។

ខ៖ បាទ! លាងហើយនិងធារី។ហើយបន្ទាប់មកទៀតកូនមានឈ្មោះអីដែរ។

កូនស្រី៖ ហើយបន្ទាប់មកខ្ញុំ។

ក៖ បាទ! ហើយអញ្ជឹងបងស្រីមានឈ្មោះអីគេដែរបងស្រី?

កូនស្រី៖ ខ្ញុំមានឈ្មោះថាមន្ទី។

ក៖ បាទ! បងមានឈ្មោះ មន្ទី។ហើយអញ្ជឹងមានឈ្មោះថា តោ
មន្ទីហើយឈ្មោះដូចកូរ៉េទៀតបងស្រី។

បងស្រី៖ ចាំ!

ខ៖ បាទ!
ពល់ថ្ងៃនិងខ្ញុំបានសុខណាសព្វថ្ងៃនិងណាបច្ចុប្បន្ននឹងហើយគេមើលយើងហើយអត់ត្រឹម
ត្រូវក៏គេអត់រវល់ជាមួយដែរណាស់។

ក៖ បាទ! កុង។

ខ៖ ហើយកាលនិងរស់ទាំងអស់គ្រាន់តែស្គមអត់បានបាយញុំាណាស់។

ក៖ បាទ!
ហើយអញ្ជឹងកុងបើនិយាយពីភរិយារបស់កុងនិងដូចថាកុងបានឃើញខ្លួនរួចឪពុកម្តាយជា
អ្នកផ្សំផ្គុំឲ្យកុង?

ខ៖ បាទ! ហើយបើនិយាយពីភរិយារបស់ខ្ញុំនិងណាស់ឪពុកម្តាយគាត់អ្នកផ្សំផ្គុំឲ្យ។

ក៖ បាទ! ហើយអញ្ជឹងឪពុកម្តាយគាត់អ្នកផ្សំផ្គុំឲ្យកុង?

ខ៖ បាទ! ហើយកាលនិងបានអ្នកជិតខាងគេអាណិតស្រឡាញ់ខ្ញុំហើយគាត់រៀបចំឲ្យខ្ញុំទៅណាស់។

ក៖ បាទ! ហើយអញ្ចឹងបានអ្នកជិតខាងជាអ្នកជួយកុង?

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងកាលនិងកុងមានបានឲ្យថ្លៃទឹកដោះឲ្យទៅម៉ាក់យាយប៉ុន្មានដែរកុង?

ខ៖ រីអត់ដឹងថាប៉ុន្មានទេលុយចាស់ៗពីដើមនិងណាស់។

ក៖ បាទ! ហើយអញ្ចឹងពីរបីពាន់ទេកុង?

ខ៖ អត់ដល់ពីរបីពាន់ទេ។

ក៖ បាទ!

ខ៖ បាទ! ហើយចាស់ពីដើមអត់មានពីរបីពាន់ទេ។

ក៖ បាទ! អត់ទេកុងដូចពីរបីរៀលយើងនិងកុង?

ខ៖ ហើយខ្ញុំអត់ដឹងថាប៉ុន្មានទេខ្ញុំអត់ដឹងដែរនិង។

ក៖ បាទ! ដឹងថាច្រើនកុង។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងកាលនិងកុងធ្វើការអីដែរកុង?

ខ៖ បាទ! កាលនិងខ្ញុំកំលោះហើយនិងហើយខ្ញុំទៅធ្វើការនៅកំពង់សោមហើយខ្ញុំកាលនិងខ្ញុំធ្វើការខាងឈើនៅមហាសាគរនិង។

ក៖ បាទ! ហើយអញ្ចឹងកុងធ្វើការនៅមហាសាគរនិងកុង។ហើយអញ្ចឹងកុងមានដែរជួបគាត់ពីមុនមកទេកុងជាមួយម៉ាក់យាយកុង?

ខ៖ ខ្ញុំធ្លាប់ជួបមុខគ្នាតើ។

ក៖ បាទ! ដូចបានជួបគាត់នៅកន្លែងណាអញ្ចឹងកុង។

ខ៖ បាទ!
ខ្ញុំធ្លាប់ជួបគាត់តើកាលពីជំនាន់អាពតនិងគាត់នៅនិងហើយខ្ញុំគេជំលៀសទៅខាងណោះទៅណា។

ក៖ បាទ!
អត់ទេកុងដូចថាពេលកុងអត់ទាន់បានរៀបការជាមួយគ្នាហើយអញ្ចឹងកុងមានដែរជួបគាត់ទេកុង?

ខ៖ ជួបមួយអ្នកណាគេ។

ក៖ ជួបជាមួយម៉ាក់យាយ។

ខ៖ ជួបជាមួយម៉ាក់យាយណា។

ក៖ ម៉ាក់យាយប្រពន្ធកុងណាស់។

ខ៖ អត់ទេអត់ដែរបានជួបគ្នាទេ។

ក៖ បាទ!ហើយអញ្ចឹងកុងអត់ដែរបានជួបគ្នាទេកុង?

ខ៖ អត់ទេអត់ដែរបានជួបគ្នាកាលនិង។

ក៖ បាទ!

ខ៖ ហើយកាលនិងខ្ញុំនៅតែធ្វើការនិង។

ក៖ បាទ! ហើយអញ្ចឹងចាស់ៗគាត់ជាអ្នករៀបចំឲ្យទៅកុង?

ខ៖ បាទ!
ហើយកាលនិងចាស់ៗគាត់រៀបចំឲ្យតែខ្ញុំអត់ដឹងខ្ញុំគិតពីធ្វើការនិងអត់បានគិតអីទេ។

ក៖ បាទ! ហើយអញ្ចឹងកុងគិតពីធ្វើការនិងកុង។

ខ៖ បាទ! ហើយយកលុយឲ្យគាត់ណាស់។

ក៖ បាទ!ហើយអញ្ចឹងកុងគិតពីធ្វើការ។

ខ៖ បាទ!
ហើយខ្ញុំតាមគាត់ទៅព្រោះអីមានអ្នកធានាច្រើនហើយគាត់ថាគ្មានអីទេស្រេចតែអញហើយឯងគិតពីធ្វើការរកលុយទុកមកឲ្យអញមក។

កៈ បាទ! ហើយអញ្ជឹងគេអ្នកមើលឲ្យកុង។

ខៈ ហើយគាត់ថារកលុយមកបានហើយ។

កៈ បាទ! ហើយអញ្ជឹងកុងមានបណ្ដាញទៀតកុង។

ខៈ បាទ! កាលនិងខ្ញុំអត់ដឹងហើយអត់រវល់ម៉ងនិងណា។

កៈ បាទ! ហើយអញ្ជឹងដឹងថ្ងៃរកលុយបានការម៉ងកុង។

ខៈ បាទ!
ហើយចាស់ៗឪពុកម៉ែមីងមាគាត់ស្រឡាញ់ខ្ញុំប៉ុន្មានគាត់អ្នករៀបចំឲ្យខ្ញុំនិងហើយគាត់ពេញកំលោះហើយអត់មានការញ៉េញ៉ាំទេ។

កៈ បាទ!
ហើយអញ្ជឹងកុងបើនិយាយពីភាសាខ្មែរយើងវិញកុងអាចសរសេរបានហើយអាចអានបានទេកុង?

ខៈ ខ្ញុំអាចអានបានតើ។

កៈ បាទ! កុងអាចអានបានហើយអញ្ជឹងកុងរៀនបានថ្នាក់ទីប៉ុន្មានដែរកាលណោះកុង?

ខៈ អត់មានថ្នាក់ខ្ញុំកាលណោះ។

កៈ បាទ!
ហើយអញ្ជឹងកាលនិងអត់មានថ្នាក់ទេកុងហើយអញ្ជឹងកុងរៀនជាមួយលោកកុង។

ខៈ បាទ! ជំនាន់គ្មានថ្នាក់ទេកាលនិងនោះខ្ញុំតែជាមួយលោកនិង។

កៈ បាទ! ហើយអញ្ជឹងកុងរៀនតែជាមួយលោកចេះម៉ងកុង។

ខៈ បាទ! កាលពីជំនាន់និងគ្មានថ្នាក់អីទេកាលណុងនោះ។

កូនស្រីៈ គាត់រៀនបានជ្រៅហើយគាត់ចេះច្រើន។

កៈ បាទ! ហើយអញ្ជឹងចេះបានច្រើនកុង។

ខៈ បាទ!
ហើយខ្ញុំចេះតែអានទៅណាហើយខ្ញុំចូលចិត្តមើលសៀវភៅហើយឲ្យតែសៀវភៅល្អខ្ញុំចេះតែគត់ទុកហើយ។

ក៖ បាទ!

ខ៖ ហើយគេថាអីឯងទេគត់ពេញតែនិងហើយខ្ញុំថាខ្ញុំស្រឡាញ់។

ក៖ បាទ!

ខ៖ ហើយអ្វីដែរប្លែកហើយរបស់អ្វីដែរប្លែកខ្ញុំយកទុក។

ក៖ បាទ!

ខ៖ ហើយរាល់ថ្ងៃនិងសៀវភៅគរនៅនិងសុទ្ធតែយូរៗ។

ក៖ បាទ!
ហើយអញ្ចឹងកុងបើនិយាយពីក្រៅភាសាខ្មែរយើងនិងបើភាសាបារាំងកុងចេះអត់កុង។

ខ៖ ខ្ញុំចេះដែរតែតិចៗ។

ក៖ បាទ! កុងចេះតិចតួច។

ខ៖ បាទ! គ្រាន់តែអានហើយនិងបានមើលឃើញ។

ក៖ បាទ! អាចមើលបានកុង។

ខ៖ បាទ! ហើយបើអាចបកប្រែអីនិងអត់ទេ។

ក៖ បាទ!

ខ៖ ហើយគ្រាន់តែចេះប្រកបហើយយល់ខ្លះៗ ។

ក៖ បាទ! ហើយអញ្ចឹងកុងបើនិយាយពីកុងរៀននិងកុងរៀននៅវត្តណាដែរកុង?

ខ៖ ហើយបានអញ្ចឹងខ្ញុំចេះនិយាយប្រាប់ថាទីមួយគេចង់ឲ្យរៀនបារាំង។

ក៖ បាទ!

ខ៖
ហើយបានហើយចាស់ៗគាត់ចេះតែថាជេសថាចុះហើយកាលសៀវភៅអាលីនិងរូបរថភ្លើង
និងណាស់។

ក៖ បាទ!

ខ៖ ហើយគេហៅ “ អ៊ី អ៊ូយ អូ អា” តិចនិងណាស់។

ក៖ បាទ!

ខ៖ ហើយបានប្រកប “ អា អ៊ូយ អូ អារ”
និងណាស់យើងនិងណាស់ហើយប្រកបថ្នាក់យើងនិង។

ក៖ បាទ!

ខ៖
ហើយពេលបានយូរទៅហើយគេថាអូរចេសអូរចុះហើយបានថារៀនតែបាវាំងនិងហើយគាត់បញ្ជូនចុះបញ្ជូនឡើងអត់សូវបានរៀនទេខ្ញុំនិងណាស់។

ក៖ បាទ! ហើយអញ្ចឹងវត្តដែរកុងរៀននិងមានឈ្មោះអីគេដែរកុង?

ខ៖ វត្តដែរខ្ញុំនិងណាវត្តក្បាលកោះយើងនិងណាស់។

ក៖ បាទ! វត្តក្បាលកោះយើងនិងកុង។

ខ៖ បាទ!

ក៖ បាទ!
ហើយអញ្ចឹងកុងពេលដែរកុងបានរៀនហើយពេលនៅក្នុងភូមិនិងកុងមានមិត្តភក្តិជិតស្និតប៉ុន្មាននាក់ដែរកុង?

ខ៖
ហើយកាលខ្ញុំនៅពីកំលោះមានមិត្តភក្តិគេធ្វើគ្រូបង្រៀននិងហើយគេស្លាប់អស់ហើយនិង។

ក៖ បាទ! ហើយគាត់ធ្វើគ្រូបង្រៀនហើយអញ្ចឹងប្រហែលជាប៉ុន្មាននាក់ដែរកុង?

ខ៖ មិត្តភក្តិខ្ញុំប្រហែលពីរបីនាក់ដែរនិងតែស្លាប់អត់ហើយ។

ក៖ បាទ! ហើយអញ្ចឹងកុងមានចាំឈ្មោះពួកគាត់ទេកុង?

ខ៖ ខ្ញុំស្គាល់តើ! មានឈ្មោះអាថៃអាអីនិងហើយសុទ្ធតែស្លាប់អស់ហើយគេធ្វើគ្រូបង្រៀន។

ក៖ បាទ! ហើយគាត់ធ្វើគ្រូបង្រៀនបាវាំងកុង?

ខ៖ គាត់និងធ្វើគ្រូបង្រៀនជំនាន់។

ក៖ បាទ! គ្រូបង្រៀនភាសាខ្មែរយើងនិងកុង។

ខ៖ បាទ! កាលជំនាន់និងគាត់និងធ្វើគ្រូបង្រៀន។

ក៖ បាទ! អញ្ចឹងគាត់ធ្វើគ្រូបង្រៀន។

ខ៖ នៅជំនាន់លន់នល់និង។

ក៖ បាទ! ហើយអញ្ចឹងពេលចូលដល់ជំនាន់អាពតគេយកទៅសម្លាប់អស់ទៅ។

ខ៖ គេសម្លាប់អស់ហើយ។

ក៖ បាទ!

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងកុងតាំងពីក្មេងរហូតដល់ធំអញ្ចឹងមានធ្លាក់ស៊ីឈ្នួលគេទេកុង?

ខ៖
ខ្ញុំធ្លាក់ស៊ីគេតើហើយបានខ្ញុំនិយាយពីការស៊ីឈ្នួលគេនិងកាលនិងខ្ញុំធ្វើកម្មករចិននិងតាំងពីជំនាន់៧០។

ក៖ បាទ! ហើយអញ្ចឹងកាលនិងបានប៉ុន្មានដែរកុង?

ខ៖ ហើយកាលពីជំនាន់ខ្ញុំបានប្រាក់ខែច្រើនកាលនិងខ្ញុំបាន១២០០ទៅ១៥៥០។

ក៖ បាទ! កុងកាលនិងបានប្រាក់ខែច្រើនដែរកុង?

ខ៖ ហើយកាលនិងវាស់ឈើ។

ក៖ បាទ! វាស់ ឈើ។

ខ៖ ហើយខ្ញុំកាលនិងដើរមើលជំនួសថៅកែគេណាស់។

ក៖ បាទ!

ខ៖ ហើយយើងជាអ្នកកត់ត្រាឲ្យគេទៅណាស់។

ក៖ បាទ! ហើយអញ្ចឹងកាលណុងកុងជាអ្នកកត់ចំនួនឈើ។

ខ៖ បាទ! កាលនិងខ្ញុំអ្នកកត់ត្រាឲ្យនិងណាស់។

ក៖ បាទ! ហើយអញ្ចឹងកាលនិងកុងឡូយដែរកុង។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ចឹងកាលនិងមានអេកូមទេកុង។

ខ៖ អត់មានទេកាលណុង។

ក៖ បាទ! បើមានអេកូមនិងឡូយម៉ងកុង។

ខ៖ បាទ! កាលពីជំនាន់អត់មានអីប្រើទេ។

ក៖ បាទ!

ខ៖ ហើយបើយើងចង់ទូរស័ព្ទពីខេត្តមួយនិងឲ្យគេនិយាយទូរស័ព្ទមក។

ក៖ បាទ!

ខ៖ ហើយកាលនិងមិនសម័យឥឡូវសម្បូរណាចង់តេទៅណាក៏បានដែរណា។

ក៖ បាទ!

ខ៖ ហើយកាលនិងរកតែកង់ជិះអត់បាន។

ក៖ បាទ!

ខ៖ ហើយបានយើងថារកគ្មានទេ។

ក៖ បាទ!

ខ៖ រកគ្មានទេអ្នកដឹកនាំល្អអញ្ចឹងនោះ។

ក៖ បាទ!

ខ៖
ហើយខ្ញុំនិយាយប្រាប់ទៅគេអត់ជឿរខ្ញុំទេហើយខ្ញុំថាអត់មានដូចហើយប្រាប់ហើយអត់ជឿរ
ទេ។

ក៖ បាទ!

ខ៖ ហើយជំនាន់មុនអត់មានទេ។

ក៖ បាទ!

ខ៖ ហើយអ្នកមានគេចេះហើយកុំថាគេមានខួរក្បាលណាស់។

ក៖ បាទ!

ខ៖ បានហើយអ្នកមានគេរកស៊ីគេដឹងជាងយើងទៀត។

ក៖ បាទ!

ខ៖
ហើយថៅកែគាត់ប្រាប់ខ្ញុំថាឯងកុំថាស្រុកខ្មែរមានរឿងអីដាក់ម៉ាកាប៉ាល់ទៅបាត់ហើយខ្ញុំថាខ្ញុំអត់ទៅចោលស្រុកមិចបាន។

ក៖ បាទ!

ខ៖ ហើយយើងអត់លុយអត់កាកយើងធ្វើមិចកើត។

ក៖ បាទ!
ហើយអញ្ជឹងកាលពីកុងនៅពីក្មេងហើយនិងពេលកុងធំហើយនៅក្នុងជីវិតរបស់កុងអញ្ជឹងកុងមានការផ្លាស់ប្តូរអ្វីខ្លះនៅក្នុងជីវិតរបស់កុងមានការលំបាកជាងសប្បាយហើយក៏មានការសប្បាយជាងលំបាកអញ្ជឹងណាស់កុង?

ខ៖ ខ្ញុំគ្មានការសប្បាយទេខ្ញុំលំបាកណាស់។

ក៖ បាទ! ហើយអញ្ជឹងកុងអត់ដែរសប្បាយមានការលំបាករហូតកុងណោះ។

ខ៖ បាទ!
គ្មានម៉ងហើយចប់ការងារហើយចូលមកដល់អាពតនិងហើយខំធ្វើចំការហើយពេលចប់មកគ្មានអីទេមានតែបាត់ដៃទទេគ្មានអង្ករមួយគ្រាប់។

ក៖ បាទ! អត់មានអីមួយគ្រាប់ទេកុង?

ខ៖ បាទ! ហើយកាលនិងមានអីទេទៅរកត្រីដូរយកអង្ករ។

ក៖ បាទ! ហើយអញ្ជឹងកាលនិងទៅរកត្រីទៅដូរអង្ករកុង។

ខ៖ បាទ!
ហើយកាលនិងយើងមានកូនច្រើនហើយបានពីរនាក់អាមកមិញនិងហើយការទៅរៀនផងហើយមកជាមួយខ្ញុំផងណាស់។

ក៖ បាទ!

ខ៖
ហើយទៅរកត្រីបានហើយលឺគេថាអរគេចាប់ទាហានហើយមានអីកូនជនបទគេចាបធ្វើទាហាននិងណាស់។

ក៖ បាទ!

ខ៖ ហើយគេចាប់កូនយើងទៅធ្វើទាហាននិង។

ក៖ បាទ!

ខ៖ ហើយកូនខ្ញុំគេចាប់ធ្វើទាហានពីរនាក់។

ក៖ បាទ!

ខ៖ ហើយគេវាយទៅរំដោះបានកំពង់ធំរួចហើយគេបញ្ជូនទៅដល់ឯណាណោះ។

ក៖ បាទ!

ខ៖ ហើយខ្ញុំថាទៅយកប្រពន្ធទៅបានគេអត់ចាប់ធ្វើទាហាន។

ក៖ បាទ!

ខ៖ ហើយគេយកទៅដាក់តាមទូកនិង។

ក៖ បាទ! កុងហើយអញ្ចឹងកុងបើនិយាយពីមុខម្ហូបកុងចូលចិត្តមុខម្ហូបអីគេដែរកុង?

ខ៖ គ្មានដឹងថាមុខម្ហូបអីគេទេ។

ក៖ បាទ! ដូចសម្លរម្ជូល ប្រហើរ សម្លឹក អីមានចូលចិត្តទេ?

ខ៖ នឹងហើយមានតែពឹននឹង។ហើយយើងអ្នកស្រុកចំការមានអីមានតែប៉ុណ្ណឹងណាស់។

កូនស្រី៖ គាត់ហូបតែបបរសរនិង។

ក៖ បាទ!

ខ៖ មានតែប៉ុណ្ណឹងគ្មានអីទេ។

ក៖ បាទ!

ខ៖
ហើយយើងធ្លាក់មានការពិបាកហើយមានការកំសត់ហើយយើងប្រាប់កូនចៅគេអត់ជឿរ
យើងទៅហើយគេថាស៊ីតែបបរនិងទេ។

ក៖ បាទ!

ខ៖ ហើយខ្ញុំថាអត់ទាន់ដឹងទេនោះ។

ក៖ បាទ! ហើយអញ្ជឹងកុងបើនិយាយពីការល្បែងប្រជាប្រិយភាពដូចជាចោលឈូង
បោះអង្គុញ ទាញព្រ័ត្តអីនឹងកុងមានចូលចិត្តលេងទេកុង?

ខ៖ អត់ទេអត់សូវចូលចិត្តទេ។

ក៖ បាទ! ហើយពេលចូលឆ្នាំខ្មែរអីមានលេងទេកុង។

ខ៖ ខ្ញុំអត់ដែរលេងម៉ងនឹងណាស់ព្រោះអីនៅតែកិច្ចការគេរហូតនិង។

ក៖ បាទ! កិច្ចការរបស់គេរហូតកុង។

ខ៖ បាទ!

ក៖ បាទ! ហើយអញ្ជឹងកុងបើការរាំការច្រៀងកុងចូលចិត្តទេកុង។

ខ៖ អត់ទេ។

ក៖ បាទ!អត់ទេកុង។

ខ៖ ហើយមានគេមកបបួលដែរហើយគេឲ្យខ្ញុំទៅលេងស្រែអំបិលហើយនាំខ្ញុំទៅរាំ។

ក៖ បាទ!

ខ៖ ហើយគេរាំជាមួយស្រីនិងទាល់តែយប់
និងហើយគេមានស្គរហើយនិងហើយគេមានកញ្ចេញពីមកលក់ផ្កាហើយកាលពីដើមមួយ
ដើមប្រាំកាកហើយពីរដើមមួយរៀល។

ក៖ បាទ!

ខ៖ មានតែប៉ុណ្ណឹងជំនាន់ដើមនោះ។

ក៖ បាទ!

ខ៖ ហើយកាលនិងខ្ញុំរាំស្រុកស្រែអំបិល ភូមិអណ្តូងទឹក។

ក៖ បាទ!

ខ៖ តែមករាំនៅស្រែអំបិល។

ក៖ បាទ!

ខ៖ ហើយគេនាំគ្នាហើយខ្ញុំថាទៅតែឯងបានទៅមើលទេឲ្យទៅរាំអត់ចេះទេ។

ក៖ បាទ! ហើយអញ្ចឹងកុងបើនិយាយពីបងប្អូនហើយកូនចៅរបស់កុងមានគេចេះលេងឧបករណ៍តន្ត្រីដូចជា ស្គរ ទ្រ ខ្លុយ រណាត ហ្គីតា ព្យាណូ ទេកុង?

ខ៖ អត់មានទេ។

ក៖ បាទ! អត់មានទេកុង?

ខ៖ បាទ! ហើយចំពោះខ្ញុំម៉ែនិងសិល្បៈហើយបើកូនចប់ទាំងអស់។

ក៖ បើកូនចប់ទាំងអស់។ហើយអញ្ចឹងកុងបើនិយាយពីផ្ទះរបស់កុងពេលដែរកុងនៅជាមួយឪពុកម្តាយរបស់កុងលក្ខណៈផ្ទះគ្បឿងឬផ្ទះស្បៅកុង?

ខ៖ ខ្ញុំផ្ទះកាលនិងផ្ទះអ៊ីនប៉ានទេ។

ក៖ បាទ! ផ្ទះអ៊ីនប៉ាន។

ខ៖ នៅឯកើតនិងណាស់។

ក៖ បាទ! ហើយអញ្ចឹងដំបូងអ្វីដែរកុង?

ខ៖ ដំបូងធម្មតាគេហៅដំបូងអ៊ីនប៉ាននិងណាស់។

ក៖ បាទ!

ខ៖ បាទ! ពេលខ្ញុំបានប្រពន្ធនិងមានផ្ទះទទឹង ៨ម៉ែត្រហើយនិងបណ្តោល១០ម៉ែត្រ។

ក៖ បាទ!

ខ៖ បាទ! ហើយគាត់ឲ្យនៅនិងទៅ។

កៈ បាទ!

ខៈ
គាត់ឲ្យនិងផ្ទះធំដែរហើយផ្ទះនិងទៀតតែរុះឆ្នាំទៅណាស់ហើយកាលនិងមានគេមកថតផ្ទះបុរាណនិងណាស់។

កៈ បាទ!

ខៈ
ពេលផ្ទះនិងបុរាណហើយបានបន្សំរឿងប៉ុលពតនិងហើយផ្ទះនិងគេទុកធ្វើដាក់កងចល័តតើ។

កៈ បាទ! ហើយអញ្ចឹងផ្ទះរបស់កុងគេទុកដាក់កងចល័តកុង។

ខៈ បាទ!នឹងហើយ។

កៈ បាទ! ឡូយណាស់កុង។

ខៈ ហើយពេលមកនិងសល់ផ្ទះនិង។

កៈ បាទ! ហើយអញ្ចឹងពេលកុងមកនៅសល់ផ្ទះនិងកុងណោះ។

ខៈ បាទ!

កៈ បាទ! ហើយបើនិយាយពីផ្ទះនិងឪពុកម្តាយកុងជាអ្នកធ្វើផ្ទាល់ឬក៏គាត់ជួយគេធ្វើកុង?

ខៈ ផ្ទះណា។

កៈ បាទ! ផ្ទះដែរឪពុកម្តាយរបស់កុងណាស់។

ខៈ អរផ្ទះនិងនៅសល់ពីរបីជំនាន់ហើយតើ។

កៈ បាទ!

ខៈ ហើយនៅនិងតាំងពីជំនាន់ហើយនាកជើងសសរតាំងពីជំនាន់ដើមមកម្លេះ។

កៈ បាទ!

ខៈ វាចូលទៅបីបួនជំនាន់ហើយខ្ញុំអត់មានរុះវាចោលណា។

កៈ បាទ!
ហើយអញ្ចឹងបើនិយាយពីការបន្តវេនពីគាត់វិញកុងមានបានចេះបន្តវេនហើយដូចជាកូរស្គរ ត្នោត ហើយនិង ត្បាញកន្ទេល ក្រមាអីទេកុង?

ខៈ អត់ទេខ្ញុំអត់មានចេះទាំងនិងផង។

កៈ បាទ!ហើយអញ្ចឹងកុងអត់ចេះទេកុង។

ខៈ បាទ!

កៈ បាទ!
ហើយអញ្ចឹងកុងកាលពីកុងនៅតូចរហូតមកដល់ធំហើយកុងមានក្ដីស្រមៃហើយនិងមានក្ដីប្រថ្នាថាចង់ក្លាយជាគ្រូបង្រៀនហើយនិងធ្វើគ្រូពេទ្យអីនិងកុងមានក្ដីស្រមៃទេកុង?

ខៈ ខ្ញុំអត់មានផងចៅ។

កៈ បាទ! ហើយអញ្ចឹងអត់មានក្ដីស្រមៃអីទេកុង?

ខៈ
ហើយខ្ញុំថាមួយជីវិតនិងអត់ហើយដូចខ្ញុំថាអញ្ចឹងណាស់ហើយបើនិយាយថាទៅធ្វើការអីដូចអត់មាននិស្ស័យអីទេហើយបើដូចហើយខ្ញុំឃើញរបស់ណាដែរប្លែកៗអីខ្ញុំយកទុក។

កៈ បាទ!

ខៈ ហើយបើនិយាយរឿងសៀវភៅវិញបើចៅកែខ្ញុំនៅវិញចិនមើលចិន។

កៈ បាទ!

ខៈ ហើយខ្មែរមើលខ្មែរ។

កៈ បាទ!

ខៈ ហើយខ្ញុំប្រកាន់ភ្ជាប់ហើយខ្ញុំជួបខ្មែរមើលខ្មែរមានតែអញ្ចឹង។

កៈ បាទ!

ខៈ ហើយចិនមើលចិនទៅហើយព្រឹកឡើងគេដោតឲ្យហើយ។

កៈ បាទ! ហើយអញ្ចឹងព្រឹកឡើងគេដោតឲ្យកុង។

ខៈ បាទ!

ក៖ ហើយយើងមើលទៅកុង។

ខ៖ បាទ!

ក៖ បាទ!
ហើយអញ្ចឹងកុងជាចុងក្រោយកុងមានពាក្យចង់ផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយរបស់កុងទេ
ថាឲ្យគាត់ខិតខំប្រឹងរៀនសូត្រអញ្ចឹងមានទេកុង?

ខ៖
ហើយខ្ញុំសព្វថ្ងៃខ្ញុំផ្ដាំតាំងពីចៅហើយខ្ញុំឲ្យទៅរៀនសាលាយ៉ៃស៊ូនៅកោះតូចនិងហើយមកវិ
ញខ្ញុំឲ្យទៅសាលារដ្ឋហើយ។

ក៖ បាទ!

ខ៖
ហើយឥឡូវវាអត់ស្ដាប់ទេហើយខ្ញុំរាល់ថ្ងៃប្រដៅថាឲ្យខំរៀនហើយខ្ញុំថាចំណេះគ្មានចោរលួ
ចបានទេ។

ក៖ បាទ!

ខ៖ ហើយបើអត់ចំណេះគឺវេទនាហើយ។

ក៖ បាទ! វេទនាហើយកុង។

ខ៖ បាទ!
ហើយសព្វថ្ងៃនិងខ្ញុំប្រដៅកូនចៅទាំងអស់និងហើយប្រដៅចៅអាមួយនោះខំរៀនហើយវាមិ
នជឿរយើងទេសព្វថ្ងៃនិង។

ក៖ បាទ!

ខ៖ ហើយសព្វថ្ងៃបក្សពួកៗសព្វថ្ងៃនិងណាស់។

ក៖ បាទ!

ខ៖ ហើយសព្វថ្ងៃនិងទៅរៀនចម្លងហើយសព្វថ្ងៃនិងចៅរៀនពីរភាសា។

ក៖ បាទ!

ខ៖ ហើយទៅរៀនខ្មែរហើយចេញពីរៀនខ្មែរទៅរៀនអង់គ្លេស។

ក៖ បាទ!

ខ៖
ហើយគ្រាន់តែចម្លងមកទុកហើយខ្ញុំថាយប់ឡើងខំប្រឹងរៀនទៅហើយតែមកដាក់តែកង់ហើយឃើញតែកង់និងប្រុចបាត់។

ក៖ បាទ! ឃើញតែកង់ប្រុចបាត់។

ខ៖ បាទ! ហើយខ្ញុំអត់ចង់ឲ្យដើរវាមានបក្សពួក។

ក៖ បាទ! ហើយអញ្ចឹងកុងបើចង់ឲ្យគាត់ជៀសវាងពីគ្រឿងញៀន បងតូចបងធំ ល្បែងស៊ីសង។

ខ៖ បាទ! រាល់ថ្ងៃនិងខ្ញុំប្រាប់ហើយថាកុំដើរលេងអត់ប្រយោជន៍ហើយកុំគេចសាលា។

ក៖ បាទ!

ខ៖ ហើយខ្ញុំប្រដៅតាំងពីក្មេងឲ្យខំប្រឹងរៀនកុំខំប្រឹងដើរហើយវាឈរផ្ទឹង។

ក៖ បាទ!

ខ៖ ហើយខ្ញុំចេះតែប្រដៅទេហើយខ្ញុំនៅទីនេះខ្ញុំមានកូនស្រីនិងហើយក្នុងឆ្នាំ ២០០០និងគេឈប់អស់ទៅគេរើសខ្ញុំធ្វើមេភូមិ។

ក៖ បាទ!

ខ៖
ហើយខ្ញុំធ្វើបានប៉ុន្មានឆ្នាំទេតែឯងនិងហើយគេឈប់អស់ហើយនិងបានឆ្នាំ១៩៩៩កើតពេទ្យជំនាន់ព្រៃកលួងនិង។

ក៖ បាទ!

ខ៖ ហើយកាលឆ្នាំ ២០០០និងហើយគេខ្ញុំរកមនុស្សដើរទៅជាមួយពេទ្យនិង។

ក៖ បាទ!

ខ៖ នៅតាមភូមិនិងអត់មានអ្នកណាធ្វើទេគេថាព្រោះអីអត់ប្រាក់ខែ។

ក៖ បាទ! អត់មានប្រាក់ខែ។

ខ៖ ហើយខ្ញុំនិងធ្វើទៅហើយខ្ញុំរកមនុស្សអត់មានទៅហើយខ្ញុំថាមើរខ្ញុំធ្វើមើរ។

ក៖ បាទ!

ខ៖ បម្រើៗហើយជាប់ទាល់រហូតនិងទៅណាស់។

ក៖ បាទ!
ហើយអញ្ជឹងកុងមានពាក្យអីជំនាន់ក្រោយទេហើយថាឲ្យគាត់ខំប្រឹងរៀនណាស់។

ខ៖
ខ្ញុំប្រាប់ថាខំប្រឹងរៀនហើយខ្ញុំចេះតែប្រដៅថាកូនចៅទាំងអស់ត្រូវខំប្រឹងរៀនឲ្យក្មេងជំនាន់ក្រោយនិងហើយគ្មានថាវណ្ណៈអីទេយើងខ្មែរត្រូវតែខំប្រឹងរៀនចេះឲ្យស្មើរប្រទេសដែរគេជឿនលឿនហើយសព្វថ្ងៃប្រទេសយើងនិងញ៉ោមញ្ញីដោយសង្គ្រាមរហូតណាស់។

ក៖ បាទ!

ខ៖
ហើយតាំងពីខ្ញុំកើតមកណាស់ហើយតិចគ្រាប់ហើយតិចគ្រាបលូនហើយគេដាក់ផ្លាក់ថាប្រទេសមានសន្តិភាពត្រូវតែហាត់ពីរបីខែហើយឥឡូវពីរបីថ្ងៃហើយគ្រប់គ្រង់ប្រទេសបាន។

ក៖ បាទ! ហើយអញ្ជឹងកុងមានពាក្យអីជាចុងក្រោយទៀតទេកុង?

ខ៖
ហើយខ្ញុំចេះតែផ្ដែផ្ដាំទៅកូនចៅទាំងអស់គ្នាណាគិតខំប្រឹងរៀនហើយបើយើងចេះជាអាវុធមួយហើយ។

ក៖ បាទ!

ខ៖ ពូកែបំផុតហើយកាំភ្លើងដែរកាំភ្លើងអត់គ្រាប់នេះពូកែណាស់ខ្លាំងណាស់។

ក៖ បាទ! ហើយអញ្ជឹងកុងមានតែប៉ុន្នានទេកុង។

ខ៖ បាទ! សូមប្រាប់ទៅអ្នកក្រោយៗផង។

ក៖ បាទ!

ខ៖
ពីបាកណាស់កាលពីជំនាន់ដើមនោះហើយខ្ញុំថាទេជំនាន់និងឥឡូវនិងគ្មានដីទំនេរទេសុទ្ធតែផ្ទះថ្មអស់ហើយ។

ក៖ បាទ!

ខ៖
ហើយកាលពីមុននិងព្រែកលៀបនិងពីមុនសុទ្ធតែព្រៃផុកតើហើយឥឡូវនិងសុទ្ធតែអគារហើយនិងផ្ទះថ្ម។

ក៖ បាទ!
អត់អីទេកុងហើយអញ្ចឹងសូមអរគុណកុងដែរកុងបានញែកពេលវេលាដ៏មានតម្លៃតែបានមកកាន់សាលារៀន BYU យើងខ្ញុំណាស់កុង។

ខ៖ ហើយសូមឲ្យកូនចៅក្រោយនិងខំប្រឹងរៀនទៅចៅ។

ក៖ បាទ!

ខ៖ គ្មានអីសំខាន់ជាងចំណេះវិជ្ជាទេ។

ក៖ បាទ!

ខ៖ ហើយជំនេះវិជ្ជានិងជាអរុធធំណាស់ហើយអរុធអត់គ្រាប់និងសំខាន់ណាស់។

ក៖ បាទ!

ខ៖
ហើយថ្ងៃក្រោយពេលយើងបានទុកនៅជាប់និងខ្លួនយើងនិងជាទ្រព្យសម្បត្តិដ៏ធំណាស់។

ក៖
ហើយចង់ជាចុងក្រោយខ្ញុំសូមអរគុណកុងហើយសូមឲ្យមានសុខភាពល្អហើយនិងសូមកូនចៅរបស់កុងមានសុខភាពល្អហើយមានការរកស៊ីអីចេះតែហូរចូលអញ្ចឹងកុងហើយអញ្ចឹងខ្ញុំសូមអរគុណកុងហើយសូមជំរាបលា។